ហុកសាវណ្ណ
សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពាក្យខ្មែរមួយបទពោលថា ឈ្លោះគ្នាក្នុងគ្រួសារដូចស្រាតកាយាបង្ហាញញាតិ ឈ្លោះគ្នាក្នុងសង្គមជាតិដូចលាតកំណាប់បង្ហាញចោរ

**web site: hoksavann.org**

ថ្ងៃទី១៥ ឧសភា ២០០៥

ពាក្យថា ឈ្លោះគ្នាក្នុងគ្រួសារដូចស្រាតកាយាបង្ហាញញាតិ មានសេចក្ដីថា  បើមានការឈ្លោះទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គមគ្រួសាររវាងម្ដាយឪពុកប្ដីប្រពន្ធកូនចៅ បើជម្លោះនោះមានលក្ខណៈស្រាល ជាជម្លោះធម្មតា នឹងស្ងប់ទៅវិញពុំឮខ្ទរខ្ទាយមកក្រៅឡើយ ។ ប៉ុន្តែបើជម្លោះនោះមានលក្ខណៈខ្លាំងដល់ថ្នាក់រកខុសត្រូវរៀងៗខ្លួន  តែងតែឮខ្ទរខ្ទាយមកខាងក្រៅ  ជួនកាលសាមីខ្លួនដែលឈ្លោះគ្នានោះ  និយាយប្រាប់ញាតិមិត្តនិងអ្នកជិតខាង  ហែកកេរ្តិ៍គ្រួសារខ្លួនឲ្យគេស្ដាប់  ដើម្បីឲ្យគេជួយកាន់ជើងទៀតផង ។ ពេលនោះហើយដែលកេរ្តិ៍ឈ្មោះអាក្រក់របស់គ្រួសារខ្លួនបានឲ្យអ្នកខាងក្រៅដឹងឮ ដោយសារតែការបាក់បែកគ្នានេះឯង ។ ពាក្យថា ដូចស្រាតកាយាបង្ហាញញាតិ គឺបង្ហាញកេរ្តិ៍ឈ្មោះអាក្រក់ដល់ញាតិ ។

ពាក្យថា ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់បង្ហាញចោរ មានសេចក្ដីថា ប្រទេសមួយទាស់ទែងគ្នាកើតឡើងដោយខ្លួនឯងក្ដី ដោយអ្នកខាងក្រៅបង្កើតឲ្យមានឡើងក្ដី  សុទ្ធតែជាហេតុពុំល្អសំរាប់ប្រទេសរបស់ខ្លួន ។ អាថ៌កំបាំងរបស់ជាតិទាំងប៉ុន្មាន បានផ្សាយឲ្យប្រទេសដទៃដឹងទាំងអស់ ។ ពាក្យថា កំណាប់ទ្រព្យ សំដៅយកទាំងទ្រព្យសម្បត្តិរបស់ជាតិ ទាំងច្បាប់ក្បួនរបៀបរក្សាឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដីជាដើម  ធ្វើឲ្យគេដឹងទាំងចំណុចខ្សោយ  ទាំងចំណុចខ្លាំងរបស់ជាតិហើយអ្នកខាងក្រៅដែលមានមហិច្ឆិតា  ក៏ឆ្លៀតឱកាសនោះចូលមកជ្រៀតជ្រែក  ឬចូលមកឈ្លានពានប្រទេសរបស់ខ្លួន  ដោយការបែកបាក់គ្នានេះឯង ដូចពួកចោរដែលតែងតែរំពៃចាំមើលពេលណា ដែលម្ចាស់ទ្រព្យភ្លេចខ្លួនឬធ្វេសប្រហែស  ក៏លួចឆក់យកទ្រព្យសម្បត្តិនោះទៅ ។ ពាក្យរបស់ខ្មែរនេះជាការរំលឹកដាស់តឿនខ្មែរគ្រប់ឋានៈឲ្យប្រុងប្រយ័ត្នរក្សាការពារឯករាជ្យជាតិ បូរណភាពទឹកដីឲ្យគង់វង់ ។ ដើម្បីរារាំងសត្រូវខាងក្រៅកុំឲ្យចូលមកឈ្លានពានប្រទេសរបស់ខ្លួនបាន  មានតែពង្រឹងផ្ទៃក្នុងកុំបែកបាក់គ្នា  ដោយខ្មែរគ្រប់ឋានៈបំពេញកិច្ចការតាមមុខងាររបស់ខ្លួនដោយឈរលើមូលដ្ឋានជាតិ ។៚